# ការទទួលបានជ័យលាភីរបស់ក្រុមនិស្សិតនៃសាកលវិទ្យាល័យបៀលប្រាយលើប្រធានបទ ការលើកកំពស់ សីលធម៌សង្គម តម្លៃស្ត្រី គ្រួសារខ្មែរ និង ( សាសនា-ដំណោះស្រាយអហឹង្សា ) ក្រោមការដឹកនាំរបស់ លោក វេជ្ជបណ្ឌិត អ៊ីន វីរជិត ប្រធាន ការិយាល័យសេវាសុខភាព នៃសាកលវិទ្យាល័យបៀលប្រាយ







ការិយាល័យសេវាសុខភាពជាផ្នែកមួយ នៃសាកលវិទ្យាល័យបៀលប្រាយ ដែលបានចូលរួមក្នុងការព្យាបាល និងពិនិត្យសុខភាព ជូនដល់និស្សិត និងបុគ្គលិកនៃសាកលវិទ្យាល័យបៀលប្រាយ ។

លំនាំតាមសកម្មភាពក្នុងកម្មវិធី វេទិការ សំនួរ ចំលើយ នៃកម្មវិធី ស្វែងយល់អំពីសីលធម៌ សង្គម តម្លៃស្ត្រី គ្រួសារខ្មែរ ។ កម្មវិធីប្រគួត( Debate ) ជុំវិញប្រធានបទ ២ "វេទិការស្វែងយល់ពីសីលធម៌សង្គម តម្លៃស្ត្រី គ្រួសារខ្មែរ និងសាសនា" និង " វេទិការស្វែងយល់ពីសីលធម៌សង្គម តម្លៃស្ត្រី គ្រួសារខ្មែរ និងដំណោះស្រាយបែបអហឹង្សា " ដែលរៀបចំដោយ គណកម្មការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី គ្រួសារខ្មែរ នៅស្ថានីយ៍ទូរទស្សជាតិកម្ពុជា នៅក្នុងបរិវេណក្រសួងព័ត៌មាន ។ ក្នុងចំណោម ព្រឹត្តិការណ៍ នៃការប្រគួតវេទិការ សំនួរ ចំលើយ សាកលវិទ្យាល័យបៀល ប្រាយបានបញ្ជូនក្រុមនិស្សិត ដែលកំពុងសិក្សាផ្នែកច្បាប់ និងគ្រប់គ្រងពាណិជ្ជកម្ម ទៅចូលរួមយ៉ាងសកម្មបំផុតក្នុងការលើកអំណះអំណាង ជាមួយក្រុមនិស្សិតមកពីបណ្តាសាកលវិទ្យាល័យផ្សេង និងមហាវិទ្យាល័យនានានៅក្នុងប្រទេស ។



សកម្មភាពក្រុមនិស្សិតក្នុងពេលប្រកួតជាមួយសាកលវិទ្យាល័យ បញ្ញាសាស្ត្រកម្ពុជា និងសាកលវិទ្យាល័យ ភ្នំពេញអន្តរជាតិ

រីឯការប្រគួត វេទិការលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រីគ្រួសារខ្មែរ ធ្វើនៅថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១០ សាកលវិទ្យាល័យបៀលប្រាយ បានបញ្ជូននិស្សិតចំនួនពីរក្រុម ដែលមានសមាជិកចំនួន ១០ រូបចូលក្នុងកម្មវិធីប្រគួតក្នុងគោលបំណង ផ្តល់ឱកាសដល់និស្សិតទទួលបាននូវការពង្រឹង និងពង្រីកចំណេះដឹងខាងជំនាញ ក៏ដូចជាចំណេះដឹងទូទៅរបស់ពួកគេនៅក្នុងសង្គម ។ ក្រុមនិស្សិត ១០ រូបដែលត្រូវបានអោយទៅប្រគួតក្នុងកម្មវិធី វេទិការស្វែងយល់អំពីសីលធម៌សង្គម តម្លៃស្ត្រី គ្រួសារខ្មែរ មានឈ្មោះដូចខាងក្រោម៖ ១- ឈួរ សុបញ្ញា ២- ហ៊ូ ប្រាថ្នា ៣ - សុវុឌ្ឍ សុបញ្ញារ័ត្ន ៤- អ៊ិត ភារម្យ ៥- ស៊ុយ ធីតា ៦- ខាន់វ៉ាន់ សេង ហេង ៧- ឡុង មុនីរ័ត្ន ៨- អ៊ុង ចាន់ណារិទ្ធ ៩- ប៊ុត ប៊ុនឈាន ១០- អ៊ុក វ៉ាន់នីន។



សកម្មភាពក្រុមនិស្សិតទទួលរង្វាន់ពីអ្នកអង្គម្ចាស់

មុននឹងបញ្ជូនក្រុមនិស្សិតទាំងនេះ ទៅចូលរួមក្នុងកម្មវិធីប្រគួត ក្រុមនិស្សិតទាំងពីរក្រុម បានទទួលការហ្វឹកហ្វឺនយ៉ាងយកចិត្តទុកដាក់បំផុតពីសំណាក់សាស្ត្រាចារ្យផ្នែកច្បាប់ លោក អឿន សុខា សាស្ត្រាចារ្យផ្នែកអក្សរសាស្ត្រខ្មែរ លោក កុក រស់ និង លោក វេជ្ជបណ្ឌិត អ៊ុន វីរៈជិត

បានធ្វើការសាកល្បងសម្តែងជាច្រើនលើក ដោយមានការកែលម្អពីគ្រូបង្វឹកក្នុងគោលបំណង កាត់បន្ថយនូវកំហុសឆ្គងរបស់ពួកគេ។ ដោយសារមានការបង្ហាត់ និងការហ្វឹកហ្វឺនយ៉ាងដិតដល់ពីសាស្ត្រាចារ្យ និងទេពកោសល្យដ៏ប៉ិនប្រសប់របស់ក្រុមនិស្សិតផងនោះក្នុងព្រឹត្តិការណ៍ប្រគួតរបស់ក្រុមនិស្សិត គឺសុទ្ធតែបង្ហាញនូវភាពប៉ិនប្រសប់របស់ពួកគេ ហើយធ្វើអោយក្រុមនិស្សិតទទួលបានជ័យលាភីទាំងពីរក្រុម គឺឈ្នះសាកលវិទ្យាល័យ បញ្ញាសាស្ត្រកម្ពុជា ទៅលើប្រធានបទ លើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី គ្រួសារខ្មែរ ដំណោះស្រាយអហឹង្សា និងឈ្នះសាកលវិទ្យាល័យ ភ្នំពេញអន្តរជាតិ ទៅលើប្រធានបទ លើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី គ្រួសារខ្មែរ និងសាសនា ឯព្រឹត្តិការណ៍ និងហេតុការណ៍ដ៏អស្ចារ្យនេះបានធ្វើអោយភ្ញៀវជាតិ និងអន្តរជាតិដែលមានវត្តមានក្នុងកម្មវិធីប្រគួត មានការជក់ចិត្តក្នុងការទស្សនា និងបានកោតសរសើរយ៉ាងខ្លាំងចំពោះទេពកោសល្យដ៏ប៉ិនប្រសប់របស់ក្រុមនិស្សិតនៃសាកលវិទ្យាល័យ បៀលប្រាយ ។



*ការថតរូបអនុស្សាវរិយ៍ជាមួយគណៈកម្មការជាតិដាក់ពន្ធុលើវិញ្ញាសារ លើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី គ្រួសារខ្មែរ និង(សាសនា-ដំណោះស្រាយអហឹង្សា)*